ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / 07 / 2016
ម៉ោង (Time/Heure): 14 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E390/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យកោះហៅសាក្សីបន្ថែមម្នាក់ និងដើមបណ្ដឹងរដ្ឋប្បវេណីបន្ថែមម្នាក់ នៅក្នុងអំឡុងបទសវនាការមន្ទីរសន្តិសុខភ្នំក្រោល

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយរបស់សហព្រះរាជអាជ្ញាដែលបានដាក់នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យកោះហៅសាក្សីបន្ថែមម្នាក់ 2-TCW-1017 និងដើមបណ្ដឹងរដ្ឋប្បវេណីបន្ថែមម្នាក់ សុខ វុត (2-TCCP-1016) ពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខភ្នំក្រោល ("សំណើ") (ឯកសារ E390)។ នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានស្ដាប់សារណាផ្ទាល់មាត់ និងចម្លើយតបផ្ទាល់មាត់ពីភាគីនានា (ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ (ភាសាអង់គ្លេស) ៤-១៨)។ នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានយល់ស្របតាមសំណើដោយផ្នែក និងបាន

សម្រេចកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត (2-TCCP-1016) ដោយសំអាងហេតុនឹងចេញតាមក្រោយ (ប្រតិចារឹក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ២-៣)។ នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានបដិសេធលើសំណើសុំកោះហៅសាក្សី 2-TCW-1017 (ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ៥១-៥២)។ អង្គជំនុំជម្រះបានស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត (2-TCCP-1016) នៅថ្ងៃទី ៣០ និង ៣១ ខែ មីនា ឆ្នាំ ២០១៦។ នៅពេលនេះ អង្គជំនុំជម្រះផ្ដល់សំអាងហេតុចំពោះសេចក្ដីសម្រេចរបស់ខ្លួនទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត (2-TCCP-1016)។

២. សហព្រះរាជអាជ្ញាលើកឡើងថា បុគ្គលបីនាក់ក្នុងចំណោមបុគ្គលប្រាំមួយនាក់ដែលខ្លួនបានស្នើសុំពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខភ្នំក្រោលនោះ បានស្លាប់ហើយ (ឯកសារ E390 កថាខណ្ឌ ២)។ សហព្រះរាជអាជ្ញាអះអាងថា សុន វុត (2-TCCP-1016) គឺជាដើមបណ្ដឹងរដ្ឋប្បវេណីតែម្នាក់គត់ដែលអាចផ្ដល់ព័ត៌មានអំពីទីតាំងឧក្រិដ្ឋកម្មនេះ។ ផ្អែកតាមសហព្រះរាជអាជ្ញា សុន វុត គឺជាអតីតកងទ័ពនៅក្នុងកងពលធំលេខ ៩២០ នៃកងទ័ពបដិវត្តន៍កម្ពុជា ដែលបានជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខ "ពិសេស" នៅជិតភ្នំមួយក្នុងស្រុក កោះញែក (ឯកសារ E390 កថាខណ្ឌ ៧)។ សហព្រះរាជអាជ្ញាអះអាងបន្ថែមទៀតថា បទចោទនានាប្រឆាំងនឹងជនជាប់ចោទ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំក្រោល រួមមាន ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខមួយធំជាងនេះ ដែលស្ថិតនៅក្រោមកងវរសេនាតូចលេខ ២ នៃតំបន់ ១០៥ ក្បែរទំនប់ ភ្នំក្រោល (ឯកសារ E390 កថាខណ្ឌ ៦)។ យោងតាមសហព្រះរាជអាជ្ញា សុន វុត (2-TCCP-1016) អាចផ្ដល់សក្ខីកម្មអំពីចំនួនអ្នកទោសដែលបានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំក្រោល រួមទាំងអំពីបញ្ហាថាតើ ភាគច្រើននៃអ្នកទោសទាំងនោះ មកពីកងពលធំ ៩២០ នៃកងទ័ពបដិវត្តន៍កម្ពុជា ឬ យ៉ាងណា (ឯកសារ E390 កថាខណ្ឌ ៧)។ ទោះបីជាទទួលស្គាល់ថា សក្ខីកម្មរបស់ សុន វុត (2-TCCP-1016) អាចរកបាននៅមុនពេលការចាប់ផ្ដើមជំនុំជម្រះក៏ដោយ ក៏សហព្រះរាជអាជ្ញាអះអាងថា វាជាប្រយោជន៍យុត្តិធម៌ ដែលសហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឲ្យដាក់សាក្សីថ្មីជំនួសសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានទទួលមរណភាពនោះ (ឯកសារ E390 កថាខណ្ឌ ៨)។

៣. នៅក្នុងការឆ្លើយតប សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនបានជំទាស់ទៅនឹងសំណើនេះទេ ហើយកត់សម្គាល់ថា ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានបញ្ជាក់អំពីចេតនារបស់គាត់ក្នុងការផ្ដល់សក្ខីកម្ម (ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ៨)។ មេធាវី

ការពារក្តី នួន ជា ក៏មិនជំទាស់ទៅនឹងសំណើនេះដែរ (ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ៨-៩)។ មេធាវីការពារក្តី ខៀវ សំផន អះអាងថា សំណើនេះគឺជាសំណើដែលដាក់យឺតពេល ពីព្រោះសំណើនេះគួរត្រូវបានដាក់នៅមុនពេលការជំនុំជម្រះលើអង្គហេតុនេះត្រូវបានចាប់ផ្តើម (ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ១០-១១)។ មេធាវីការពារក្តី ខៀវ សំផន ក៏អះអាងផងដែរថា វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ជាករណីពិសេស ហើយគួរតែត្រូវបានផ្អែកទៅលើតែក្នុងករណីសុំស្តាប់សក្ខីកម្មបុគ្គលបន្ថែមដែលមិនត្រូវបានកំណត់អត្តសញ្ញាណកាលពីមុនប៉ុណ្ណោះ ហើយថា ការផ្អែកទៅលើវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនៅក្នុងស្ថានភាពបច្ចុប្បន្ននេះ នឹងប៉ះពាល់ដល់ការត្រៀមរៀបចំរបស់មេធាវីការពារក្តី (ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ១១-១២)។ មេធាវីការពារក្តីបានបញ្ជាក់ទៀតថា យោងតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពុំមានព័ត៌មានពាក់ព័ន្ធនឹងមន្ទីរសន្តិ-សុខភ្នំក្រោលទេ (ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ១៤)។ នៅក្នុងការឆ្លើយតប សហព្រះរាជអាជ្ញាលើកឡើងថា អង្គហេតុស្តីអំពីមន្ទីរសន្តិសុខភ្នំក្រោល បានចាប់ផ្តើមមុនពេលកំណត់ ដោយសារតែស្ថានភាពពិសេសមួយនៅក្នុងការកំណត់កាលវិភាគសវនាការ និងអះអាងជាថ្មីម្តងទៀតថា ហេតុផលក្នុងការកោះហៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គឺដោយសារតែមរណភាពរបស់សាក្សីផ្សេងទៀតដែលសហព្រះរាជអាជ្ញាបានស្នើសុំពីមុន (ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ១៦)។ ទាក់ទងនឹងភាពពាក់ព័ន្ធនៃដើមបណ្តឹងរដ្ឋ-ប្បវេណីរូបនេះ សហព្រះរាជអាជ្ញាអះអាងថា មន្ទីរសន្តិសុខដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានឃុំខ្លួននោះ គឺស្ថិតនៅទីតាំងនៃមន្ទីរសន្តិសុខភ្នំក្រោល (ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ទំព័រ ១៧)។

៤. អង្គជំនុំជម្រះរម្លឹកថា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីទាំងអស់ អង្គជំនុំជម្រះអាចទទួលយកភស្តុតាងទាំងឡាយណាដែលអង្គ-ជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភស្តុតាងនោះក៏បំពេញផងដែរនូវបទដ្ឋាន*ការបញ្ជាក់បឋម*នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង យថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំឱ្យទទួលយកភស្តុតាងថ្មី ស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏តម្រូវផងដែរថា ភាគីដែលបានស្នើសុំឱ្យទទួលយកភស្តុតាងថ្មីត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។

ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាងដែលខ្លួនស្នើសុំដាក់នោះពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ ឬ ពុំអាចត្រូវបានរកឃើញទោះបីជាបានខិតខំព្យាយាមយ៉ាងសមស្របហើយក៏ដោយ។ ទោះបីជាយ៉ាងណា នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភស្តុតាងនានាដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមទាំងក្នុងករណីដែលភស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងក្នុងករណីដែលប្រយោជន៍យុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា និងករណីដែលឯកសារដែលបានស្នើសុំដាក់នេះ គឺជាភស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ (ឯកសារ E383/2 កថាខណ្ឌ ៣)។

៥. ទោះបីជាអង្គជំនុំជម្រះទទួលស្គាល់ថា ភាគីទើបតែបានទទួលដំណឹងនៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១៦ ប៉ុណ្ណោះថា ពាក់កណ្តាលនៃចំនួនសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាសម្រាប់អង្គហេតុនេះ បានស្លាប់ហើយក៏ដោយ (អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦) ក៏អង្គជំនុំជម្រះកត់សម្គាល់ថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុន វុត (2-TCCP-1016) អាចរកមើលបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះក្នុងសំណុំរឿង ០០២ ពីព្រោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះត្រូវបានធ្វើឡើងនៅក្នុងខែ សីហា ឆ្នាំ ២០០៩ ហើយក្រោយមកក៏ត្រូវបានដាក់ទៅក្នុងសំណុំរឿង ០០២ នៅក្នុងឆ្នាំ ២០១០។ ដូច្នេះ ទោះបីជាមានការទទួលស្គាល់អំពីលក្ខណៈពិសេសនៃកាលៈទេសៈទាំងនេះ និងមានការកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានខិតខំប្រឹងប្រែងដោយសមស្របនៅក្នុងការដាក់សំណើនេះ បន្ទាប់ពីមានការជូនដំណឹងអំពីស្ថានភាពនេះតាមរយៈអ៊ីម៉ែលក៏ដោយ ក៏អង្គជំនុំជម្រះនៅតែពិចារណាឃើញថា សំណើនេះគឺជាសំណើដែលដាក់យឺតពេល ដោយសារតែសក្ខីកម្មដែលបានស្នើឡើងនោះ អាចរកមើលបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះ។ ទោះបីយ៉ាងណាក្តី អង្គជំនុំជម្រះនឹងពិចារណាថាតើ វាជាប្រយោជន៍នៃយុត្តិធម៌ ក្នុងការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរ ឬ យ៉ាងណា។

៦. ផ្អែកតាមពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុន វុត (2-TCCP-1016) គាត់ត្រូវបានចាត់តាំងជាប្រធានកងអនុសេនាធំពិសេសលេខ ៩២០ នៅក្នុងខេត្តមណ្ឌលគិរី។ ក្រោយមក គាត់ក៏ត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅមន្ទីរសន្តិសុខ "ពិសេស" នៅក្នុងស្រុកកោះ-ញែកអស់រយៈពេលប្រហែលមួយឆ្នាំ (E3/6760a ទំព័រ ១)។ អង្គជំនុំជម្រះកត់សម្គាល់ថា

ទោះបីជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សុន វុត (2-TCCP-1016) មិនបានបញ្ជាក់ឱ្យបានច្បាស់ថា គាត់ត្រូវបានគេឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខភ្នំក្រោលក៏ដោយ ក៏ទីតាំងដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានរៀបរាប់នោះ គឺត្រូវគ្នានឹងទីតាំងមន្ទីរសន្តិសុខភ្នំក្រោលដែរ (ដីកាដំណោះស្រាយ សំណុំរឿង ០០២ កថាខណ្ឌ ៦២៥-៦២៦, ឯកសារ E3/6760a ទំព័រ ១)។ អង្គជំនុំជម្រះយល់ឃើញថា ការស្តាប់សក្ខីកម្មរបស់ សុន វុត (2-TCCP-1016) មានសារៈសំខាន់ ពីព្រោះគាត់គឺជាដើមបណ្តឹងរដ្ឋប្បវេណីតែម្នាក់គត់ដែលអាចផ្តល់ភ័ស្តុតាងអំពីទីតាំងឧក្រិដ្ឋកម្មនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះក៏ទំនងជាអាចផ្តល់ព័ត៌មានផងដែរ ទាក់ទងទៅនឹងអង្គហេតុស្តីអំពីការចេញបទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍ (ឯកសារ E3/6760a ទំព័រ ២)។ ទាក់ទងនឹងការលើកឡើងរបស់មេធាវីការពារក្តី ខៀវ សំផន ដែលថា វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង គួរត្រូវបានយកមកប្រើតែក្នុងករណីពិសេសនោះ អង្គជំនុំជម្រះយល់ឃើញថា វិធាននេះអនុញ្ញាតឱ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មរបស់បុគ្គល ឬ ទទួលយកភ័ស្តុតាងថ្មីទាំងឡាយ ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ អង្គជំនុំជម្រះជឿជាក់ថា ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ *តាមការបញ្ជាក់បឋម* ពាក់ព័ន្ធទៅនឹងអង្គហេតុមន្ទីរសន្តិសុខភ្នំក្រោល និងការចេញបទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការស្តាប់សក្ខីកម្មរបស់ សុន វុត (2-TCCP-1016) នឹងមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ហើយវាជាប្រយោជន៍នៃយុត្តិធម៌ក្នុងការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

៧. ដូច្នេះ អង្គជំនុំជម្រះសម្រេចស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សុន វុត (2-TCCP-1016)។ នេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E390។